# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍ស្តីអំពីការបណ្តុះបណ្តាលបំប៉ន ប្រព័ន្ធគ្រប់គ្រងទិន្នន័យ សំរាប់មន្ត្រីផ្នែកគ្រប់គ្រងទិន្នន័យថ្នាក់ខេត្ត-ក្រុង

Refresher Training on Data Management System
for Provincial Data Management Officers

**នៅសណ្ឋាគារអរុណរះII ខេត្តមណ្ឌលគិរី**

ថ្ងៃទី ១៨-២០ ខែតុលា ឆ្នាំ ២០១១



NCHADS

GFATM-SSF HIV

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# របាយការណ៍ស្តីអំពីការបណ្តុះបណ្តាលបំប៉ន ប្រព័ន្ធគ្រប់គ្រងទិន្នន័យ

# សំរាប់មន្ត្រីផ្នែកគ្រប់គ្រងទិន្នន័យថ្នាក់ខេត្ត-ក្រុង

Refresher Training on Data Management System
for Provincial Data Management Officers

**នៅសណ្ឋាគារអរុណរះII ខេត្តមណ្ឌលគីរី**

ថ្ងៃទី ១៨-២០ ខែតុលា ឆ្នាំ ២០១១

វគ្គបណ្តុះបណ្តាលបំប៉នស្តីអំពីប្រព័ន្ធគ្រប់គ្រងទិន្នន័យ សំរាប់មន្ត្រីគ្រប់គ្រងទិន្នន័យថ្នាក់ខេត្ត-ក្រុង បានប្រព្រឹត្តទៅនៅសណ្ឋាគារអរុណរះII ខេត្តមណ្ឌលគីរី ពីថ្ងៃទី ១៨ ដល់ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១, ដែលរៀបចំឡើងដោយផ្នែកគ្រប់គ្រងទិន្នន័យនៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ដោយទទួលបាននូវការឧបត្ថម្ភថវិកាពីមូលនិធិសកល GFATM-SSF។ វគ្គបណ្តុះបណ្តាលនេះគឺធ្វើឡើងក្នុងគោលបំណងផ្តល់នូវពត៌មានថ្មីៗដែលមជ្ឈមណ្ឌលជាតិបាននិងកំពុងរៀបចំដាក់អោយប្រើប្រាស់-ធ្វើការផ្លាស់ប្តូរបទពិសោធន៏គ្នាទៅវិញទៅមក លើការងារគ្រប់គ្រងទិន្នន័យរបស់ខេត្តនិមួយៗ-រំលឹកឡើង វិញអំពីយន្តការការងារដែលត្រូវអនុវត្ត ជាពិសេសលើតួនាទីក្នុងការទទួលខុសត្រូវ និងភារកិច្ចដែលត្រូវអនុវត្តជាប្រចាំ ។

វគ្គបណ្តុះបណ្តាលបំប៉ននេះ មានការចូលរួមពីមន្ត្រីផ្នែកគ្រប់គ្រងទិន្នន័យ ២០ខេត្ត (៧៣នាក់) មន្ត្រីបញ្ចូលទិន្នន័យចំនួន ៣៧នាក់, មន្ត្រីទទួលខុសត្រូវការងារវិធីសាស្រ្តឆ្លើយតបរួមគ្នាចំនួន ៦នាក់ មន្ត្រីមកពីមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងមន្ត្រីសម្របសម្រួលខេត្តមណ្ឌលគីរី ។

<u>គណៈធិបតី</u> :

| | | | |
|---|---|---|---|
| លោកគ្រូពេទ្យ | គុជ | វណ្ណា | អនុប្រធានមន្ទីរសុខាភិបាលខេត្តមណ្ឌលគីរី |
| លោកវេជ្ជបណ្ឌិត | សឺរិត | សុវណ្ណារិទ្ធ | ប្រធានផ្នែកថែទាំជំងឺអេដស៏មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ |
| លោកគ្រូពេទ្យ | ជា | ចំណោន | អនុប្រធានផ្នែកគ្រប់គ្រងទិន្នន័យមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ |

<u>គ្រូសំរួលវគ្គ</u> :

| | | | |
|---|---|---|---|
| លោក | ម៉ម | សុវត្ថា | ប្រធានផ្នែកគ្រប់គ្រងទិន្នន័យមជ្ឈមណ្ឌលជាតិ |
| លោកគ្រូពេទ្យ | ជា | ចំណោន | អនុប្រធានផ្នែកគ្រប់គ្រងទិន្នន័យមជ្ឈមណ្ឌលជាតិ |

និងមន្ត្រីផ្នែកគ្រប់គ្រងទិន្នន័យរបស់មជ្ឈមណ្ឌលជាតិ

**សកម្មភាពនៃវគ្គបណ្តុះបណ្តាល :**

**ថ្ងៃទី ១ : ថ្ងៃទី ១៨ ខែតុលា ឆ្នាំ២០១១**

ពេលព្រឹក

ចាប់ពីម៉ោង ៧:៣០នាទី ដល់ម៉ោង ៨:០០: ការចុះឈ្មោះសិក្ខាកាមដែលមកចូលរួមទាំងអស់, ដែលក្នុងនោះមាន :

- ខេត្ត បន្ទាយមានជ័យ :
  - មន្ត្រីគ្រប់គ្រងទិន្នន័យ ចំនួន ០៤ នាក់
  - មន្ត្រីបញ្ចូលទិន្នន័យ ចំនួន ០៤ នាក់
- ខេត្ត បាត់ដំបង
  - មន្ត្រីគ្រប់គ្រងទិន្នន័យ ចំនួន ០៤ នាក់
  - មន្ត្រីបញ្ចូលទិន្នន័យ ចំនួន ០៥ នាក់
  - មន្ត្រីទទួលខុសត្រូវការងារវិធីសាស្ត្រឆ្លើយតបរួមគ្នា ចំនួន ០១ នាក់
- ខេត្ត កំពង់ចាម
  - មន្ត្រីគ្រប់គ្រងទិន្នន័យ ចំនួន ០៤ នាក់
  - មន្ត្រីបញ្ចូលទិន្នន័យ ចំនួន ០៧ នាក់
- ខេត្ត កណ្តាល
  - មន្ត្រីគ្រប់គ្រងទិន្នន័យ ចំនួន ០៤ នាក់
  - មន្ត្រីបញ្ចូលទិន្នន័យ ចំនួន ០២ នាក់
- ខេត្ត កោះកុង មន្ត្រីគ្រប់គ្រងទិន្នន័យ ចំនួន ០៣ នាក់
- ខេត្ត ព្រៃវែង
  - មន្ត្រីគ្រប់គ្រងទិន្នន័យ ចំនួន ០៣ នាក់
  - មន្ត្រីបញ្ចូលទិន្នន័យ ចំនួន ០១ នាក់
  - មន្ត្រីទទួលខុសត្រូវការងារវិធីសាស្ត្រឆ្លើយតបរួមគ្នា ចំនួន ០១ នាក់
- ខេត្ត ពោធិសាត់
  - មន្ត្រីគ្រប់គ្រងទិន្នន័យ ចំនួន ០៤ នាក់
  - មន្ត្រីបញ្ចូលទិន្នន័យ ចំនួន ០១ នាក់
  - មន្ត្រីទទួលខុសត្រូវការងារវិធីសាស្ត្រឆ្លើយតបរួមគ្នា ចំនួន ០១ នាក់
- ខេត្ត សៀមរាប
  - មន្ត្រីគ្រប់គ្រងទិន្នន័យ ចំនួន ០៤ នាក់
  - មន្ត្រីបញ្ចូលទិន្នន័យ ចំនួន ០៣ នាក់
  - មន្ត្រីទទួលខុសត្រូវការងារវិធីសាស្ត្រឆ្លើយតបរួមគ្នា ចំនួន ០១ នាក់
- ខេត្ត ស្វាយរៀង
  - មន្ត្រីគ្រប់គ្រងទិន្នន័យ ចំនួន ០៤ នាក់
  - មន្ត្រីបញ្ចូលទិន្នន័យ ចំនួន ០១ នាក់

- ខេត្ត តាកែវ
  - មន្ត្រីគ្រប់គ្រងទិន្នន័យ ចំនួន ០៣ នាក់
  - មន្ត្រីបញ្ចូលទិន្នន័យ ចំនួន ០២ នាក់
  - មន្ត្រីទទួលខុសត្រូវការងារវិធីសាស្ត្រឆ្លើយតបរួមគ្នា ចំនួន ០១ នាក់
- ខេត្ត ព្រះសីហនុ មន្ត្រីគ្រប់គ្រងទិន្នន័យ ចំនួន ០៤ នាក់
- ខេត្ត កំពង់ឆ្នាំង មន្ត្រីគ្រប់គ្រងទិន្នន័យ ចំនួន ០៤ នាក់
- ខេត្ត កំពង់ធំ មន្ត្រីគ្រប់គ្រងទិន្នន័យ ចំនួន ០៣ នាក់
- ខេត្ត កំពង់ស្ពឺ
  - មន្ត្រីគ្រប់គ្រងទិន្នន័យ ចំនួន ០៤ នាក់
  - មន្ត្រីបញ្ចូលទិន្នន័យ ចំនួន ០១ នាក់
- ខេត្ត កំពត
  - មន្ត្រីគ្រប់គ្រងទិន្នន័យ ចំនួន ០៤ នាក់
  - មន្ត្រីបញ្ចូលទិន្នន័យ ចំនួន ០១ នាក់
  - មន្ត្រីទទួលខុសត្រូវការងារវិធីសាស្ត្រឆ្លើយតបរួមគ្នា ចំនួន ០១ នាក់
- ខេត្ត ក្រចេះ មន្ត្រីគ្រប់គ្រងទិន្នន័យ ចំនួន ០៤ នាក់
- ខេត្ត ឧត្តរមានជ័យ មន្ត្រីគ្រប់គ្រងទិន្នន័យ ចំនួន ០៤ នាក់
- ខេត្ត ស្ទឹងត្រែង មន្ត្រីគ្រប់គ្រងទិន្នន័យ ចំនួន ០៣ នាក់
- ខេត្ត ប៉ៃលិន មន្ត្រីគ្រប់គ្រងទិន្នន័យ ចំនួន ០៤ នាក់
- ខេត្ត ព្រះវិហារ មន្ត្រីគ្រប់គ្រងទិន្នន័យ ចំនួន ០៤ នាក់
- មន្ត្រីបញ្ចូលទិន្នន័យមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ចំនួន ០២ នាក់
- មន្ត្រីបញ្ចូលទិន្នន័យមន្ទីរពេទ្យកុមារជាតិ ចំនួន ០២ នាក់
- មន្ត្រីបញ្ចូលទិន្នន័យមន្ទីរពេទ្យបង្អែកសម្តេចឳ ចំនួន ០១ នាក់
- មន្ត្រីបញ្ចូលទិន្នន័យមន្ទីរពេទ្យបង្អែកមានជ័យ ចំនួន ០១ នាក់
- មន្ត្រីបញ្ចូលទិន្នន័យមណ្ឌលសុខភាពចំការដូង ចំនួន ០២ នាក់
- មកពីមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ចំនួន ២២ នាក់
- តំណាងអង្គការសុខភាពគ្រួសារអន្តរជាតិ (FHI) ចំនួន ២ នាក់

បន្ទាប់ពីការចុះឈ្មោះសិក្ខាកាមដែលមកចូលរួមរួចមក នៅវេលាម៉ោង ៨:០០ វគ្គបណ្តុះបណ្តាលបានចាប់ផ្តើមដំណើរការរបស់ខ្លួន ។ ជាដំបូងលោក ផាត់ វាសនា មន្ត្រីផ្នែកគ្រប់គ្រងទិន្នន័យមជ្ឈមណ្ឌលជាតិតំណាងអោយអ្នករៀបចំកម្មវិធី បានប្រកាសគណធិបតី និងអញ្ជើញអង្គសិក្ខាសាលាទាំងមូលក្រោកឈរដើម្បីគោរពភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា។ បន្ទាប់ពីបានប្រកាសរបៀបវីរៈនៃកិច្ចប្រជុំ និងអង្គហេតុរបស់ផ្នែកគ្រប់គ្រងទិន្នន័យរួចមក ជាកិច្ចចាប់ផ្តើម លោកគ្រូពេទ្យ ជា ចំណាន អនុប្រធានផ្នែកគ្រប់គ្រងទិន្នន័យមជ្ឈមណ្ឌលជាតិប្រយុទ្ធ នឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានមានចំណាប់អារម្មណ៍ និងមតិសំណេះសំណាលទៅកាន់សិក្ខាកាម។ ជាបន្តទៅទៀត លោកគ្រូពេទ្យ គុជ វណ្ណា អនុប្រធានមន្ទីរសុខាភិបាលខេត្តមណ្ឌលគីរី បានមានមតិសំណេះសំណាល ដោយបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់សិក្ខាកាមទាំងអស់ដែលបានធ្វើដំណើរមកចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ ដើម្បីទទួលយកនូវចំណេះដឹងសំរាប់យកទៅអនុវត្តន៍ការងាររបស់ខ្លួនដែលត្រូវបំពេញដើម្បីឆ្លើយតបទៅនឹងតំរូវការរបស់មជ្ឈមណ្ឌលជាតិ ។ លោកគ្រូពេទ្យ គុជ វណ្ណា ក៏បានលើកយកនូវសមិទ្ធិផល

ការងាររបស់មន្ទីរសុខាភិបាលខេត្តដែលបានអនុវត្តកន្លងមកមកបង្ហាញ និង ចែករំលែកនូវបទពិសោធន៍មួយចំនួនដែលខេត្តរបស់លោកបានជួបកន្លងមក ជាពិសេសលោកបានផ្តាំផ្ញើអោយសិក្ខាកាមទាំងអស់ត្រូវធ្វើយ៉ាងណា យកចិត្តទុកដាក់ក្នុងការរៀនសូត្រតាមរយៈការបណ្តុះបណ្តាលនេះ ដើម្បីយកទៅអនុវត្តការងារដែលត្រូវបំពេញនៅតាមខេត្តរៀង១ខ្លួន។ បន្ថែមទៅទៀតលោកក៏បានលើកយកពីការអភិវឌ្ឍន៍របស់ខេត្តទាំងវិស័យទូរគមនាគមន៍ និងរមណីយដ្ឋានធម្មជាតិនានាជូនដល់សិក្ខាកាមដែលមានបំណងចង់ទៅទស្សនាបន្ទាប់ពីការប្រជុំចប់ ។ បន្ទាប់ពីមានមតិសំណេះសំណាល និងផ្តាំផ្ញើរួចមកលោកអនុប្រធានមន្ទីរបានធ្វើការប្រកាសបើកវគ្គបណ្តុះបណ្តាលចាប់ពីពេលនោះតទៅ។

បន្ទាប់ពីការប្រកាសបើកវគ្គបណ្តុះបណ្តាលរួចមក វគ្គបណ្តុះបណ្តាលបានចាប់ផ្តើមដំណើរការការងាររបស់ខ្លួន តាមកម្មវិធី និងពេលវេលាកំណត់ ដោយបានចាប់ផ្តើមធ្វើការបង្ហាញពីលទ្ធផលនានាដែលបានអនុវត្តកន្លងមក និងទិសដៅការងារដែលត្រូវអនុវត្តបន្តលើការងារថែទាំ និងព្យាបាលជំងឺអេដស៍ មានជាអាទិ៍ :

- ការធ្វើតេស្តមុនវគ្គសិក្សា (Pre-test): ដែលតំរូវអោយសិក្ខាកាមទាំងអស់បំពេញនូវសំនួរមួយចំនួន ដើម្បីចង់ដឹងថាមុនពេលវគ្គសិក្សា តើកំរិតនៃការយល់ដឹងរបស់ពួកគាត់ស្ថិតនៅកំរិតណា។ ណែនាំដោយក្រុមការងាររបស់មជ្ឈមណ្ឌលជាតិ
- ការបង្ហាញអំពីការងារសេវាថែទាំព្យាបាលបន្តសំរាប់អ្នកផ្ទុកមេរោគអេដស៍ (Continuum of Care) ដោយលោកវេជ្ជ. ស៊ិត សុវណ្ណរិទ្ធ បានបង្ហាញនូវសកម្មភាពមួយចំនួនដែលទាក់ទងទៅនិងការងារដែលក្រុមផ្នែកថែទាំអ្នកជំងឺអេដស៍របស់មជ្ឈមណ្ឌលជាតិបានធ្វើ និងទិសដៅខាងមុខដែលបានគ្រោងទុក ។
- ការបង្ហាញអំពីសកម្មភាពវិធីសាស្រ្តឆ្លើយតបរួមគ្នា (Linked Response) ដោយលោក ស៊ុន សុខលេង បានបង្ហាញនូវពត៌មានមួយចំនួនដែលទាក់ទងទៅនិងគោលបំណងនៃការធ្វើសកម្មភាព និងវិធីសាស្រ្តយ៉ាងណាដើម្បីសំរេចនៅគោលដៅដែលថ្នាក់ជាតិចង់បាន ជាពិសេសការធ្វើអោយមានទំនាក់ទំនងគ្នារវាងសេវានៅតាមមណ្ឌលសុខភាព ជាមួយនិងសេវាសុខាភិបាលនៅតាមបណ្តាស្រុកប្រតិបត្តិ ដើម្បីតាមដានស្រ្តីមានផ្ទៃពោះដែលមានផ្ទុកមេរោគអេដស៍ និងទារកដែលកើតពីម្តាយដែលមានផ្ទុកមេរោគអេដស៍ ក្នុងទិសដៅកាត់បន្ថយការចំលងមេរោគអេដស៍ពីម្តាយទៅកូន ដោយបានពិភាក្សាគ្នាធ្វើយ៉ាងណាអោយការប្រមូលទិន្នន័យមានភាពរលូន និងត្រឹមត្រូវ។

<u>ពេលរសៀល</u>

- ការបង្ហាញបន្តអំពីសកម្មភាពវិធីសាស្រ្តឆ្លើយតបរួមគ្នា (Linked Response) ដោយ លោក ស៊ុន សុខលេង បានធ្វើការពិភាក្សាបន្តអំពីចម្ងល់មួយចំនួនដែលមន្រ្តីគ្រប់គ្រងទិន្នន័យខេត្ត និងមន្រ្តីទទួលខុសត្រូវវិធីសាស្រ្តឆ្លើយតបរួមគ្នា ។
- ការបង្ហាញអំពីប្រពន្ធ័គ្រប់គ្រងទិន្នន័យ STD ដោយលោកស្រី ឡាញ់ ចរិយា បានលើកយកនូវចំនុចកែសំរួលនិងពត៌មានផ្សេងទៀតដែលតំរូវអោយមន្រ្តីគ្រប់គ្រងទិន្នន័យធ្វើការត្រួតពិនិត្យអោយបានច្បាស់និងត្រឹមត្រូវមុននិងបញ្ជូនមកកាន់មជ្ឈមណ្ឌលជាតិ ដែលមកដល់បច្ចុប្បន្នមានកន្លែងពិនិត្យនិងព្យាបាលជំងឺកាមរោគមាន ៣២ កន្លែង។
- ការបង្ហាញអំពីប្រពន្ធ័គ្រប់គ្រងទិន្នន័យ VCCT ដោយលោក ឡេង ច័ន្ទរតនា និងលោក ផាត់ វ៉ាសនា បានលើកយកនូវចំនុចកែសំរួលនិងពត៌មានផ្សេងទៀតដែលតំរូវអោយមន្ត្រីគ្រប់គ្រងទិន្នន័យធ្វើការត្រួតពិនិត្យអោយបានច្បាស់និងត្រឹមត្រូវមុននិងបញ្ជូលទៅកាន់ប្រព័ន្ធគ្រប់គ្រងទិន្នន័យ VCCT

រួចបញ្ជូនមកកាន់មជ្ឈមណ្ឌលជាតិ ព្រោះថាចំនួនសេវាធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសំងាត់ពង្រីកកាន់តែច្រើនកន្លែងមានរហូតដល់ ២៥២ កន្លែងទូទាំងប្រទេស ។

- ការបង្ហាញអំពីប្រពន្ធ័គ្រប់គ្រងទិន្នន័យ Home Base Care ដោយលោក ឡេង ច័ន្ទរតនា បានលើកយកនូវចំនុចកែសំរួលនិងពត៌មានផ្សេងទៀតមកបង្ហាញដែលទាមទារអោយមន្រ្តីគ្រប់គ្រងទិន្នន័យធ្វើការត្រួតពិនិត្យអោយបានច្បាស់និងត្រឹមត្រូវមុននិងធ្វើរបាយការណ៍រួម រួចបញ្ជូនមកកាន់មជ្ឈមណ្ឌលជាតិ មកដល់បច្ចុប្បន្នចំនួនក្រុមថែទាំអ្នកជំងឺអេដស៍តាមផ្ទះមាន ៣៣៨ក្រុមគ្របដណ្តប់ ៨៦១មណ្ឌលសុខភាព ក្នុងចំណោម៧២ស្រុកប្រតិបត្តិ ទូទាំង១៩ ខេត្ត-ក្រុង ។

## ថ្ងៃទី ២ : ថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០១១

ពេលព្រឹក

- ការបង្ហាញអំពីការងារយុទ្ធសាស្រ្ត Three I's ដោយលោក ផាត់ វាសនា, គឺជាការងារថ្មីមួយដែលបន្ថែមទៅលើអ្នកបម្រើការងារនៅសេវា OI-ART ដើម្បីជំរុញអោយធ្វើការស្រាវជ្រាវរករោគសញ្ញាជំងឺរបេងចំពោះអ្នកជំងឺអេដស៍ថ្មីទាំងអស់ដែលទទួលការព្យាបាល OI-ART អោយប្រាកដថាអ្នកជំងឺទាំងនោះមានរោគសញ្ញាជំងឺរបេងដែរឺទេ ប្រសិនបើមានត្រូវជំរុញធ្វើការព្យាបាលដោយការផ្តល់ឱសថ Isoniazide អោយបានលឿនបំផុតដើម្បីកុំអោយអ្នកជំងឺអាចឆ្លងមេរោគរបេងបានដោយប្រការណាមួយ ។ លោក ផាត់ វាសនា ក៏បានលើកយកទំរង់ពត៌មានមួយចំនួនដែលត្រូវបន្ថែមដើម្បីអោយស្របទៅនិងយុទ្ធសាស្រ្ត Three I's ដោយពន្យល់យ៉ាងក្បោះក្បាយក្នុងនោះមាន:
  - ចំនុចកែសំរួលឡើញវិញនៅលើទំរង់ពត៌មានរបស់អ្នកជំងឺមកពិនិត្យ (ទំរង់ខ) មនុស្សចាស់
  - លិខិតបញ្ជូន
  - បញ្ជីចុះឈ្មោះអ្នកជំងឺឱកាសនិយម
  - បញ្ជីចុះឈ្មោះអ្នកជំងឺព្យាបាលដោយឱសថ ART
  - របាយការណ៍ប្រចាំត្រីមាសថ្មីស្តីពីការព្យាបាលជំងឺឱកាសនិយមមុន ART
  - របាយការណ៍ប្រចាំត្រីមាសថ្មីស្តីពីការព្យាបាលដោយ ART

  សិក្ខាកាមបានសាកសួរនូវសំណួរជាច្រើនដែលទាក់ទងទៅនិងយុទ្ធសាស្រ្តនេះ ដោយមានការពន្យល់និង ឆ្លើយសំណួរដ៏ជាក់លាក់ធ្វើអោយសិក្ខាកាមទាំងអស់អាចទទួលបាននូវចំណេះដឹងថ្មីដើម្បីយកទៅបំពេញការងារ ។

ពេលរសៀល

- ការបង្ហាញអំពីការបង្ការជាវិជ្ជមាន (Positive Prevention) ដោយលោក ផាត់ វាសនា នេះជាការងារថ្មីមួយដែលបន្ថែមទៅលើអ្នកបម្រើការងារនៅសេវា OI-ART ដើម្បីជំរុញអោយមានការផ្តល់ប្រឹក្សា និងណែនាំអោយអ្នកជំងឺដែលបានទទួលការព្យាបាលជំងឺឱកាសនិយម និងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ បានទទួលការពន្យាកំណើតតាមវិធីណាមួយដែលសមស្របសំរាប់ពួកគាត់, ផ្តល់ប្រឹក្សាអំពីការថែទាំខ្លួនកុំអោយឆ្លងមេរោគរបេង, ផ្តល់ប្រឹក្សាអំពីការប្រើប្រាស់ថ្នាំពន្យាអោយបានត្រឹមត្រូវនិងទៀងទាត់, ការប្រើប្រាស់ស្រោមអនាម័យអោយបានត្រឹមត្រូវ, ការបង្ការកុំអោយឆ្លងជំងឺកាមរោគ ចំនុចទាំងនេះនឹងត្រូវរាយការណ៍ចូលទៅក្នុងរបាយការណ៍ OI-ART កន្លែងអ្នកជំងឺថ្មី OI និងអ្នកជំងឺថ្មី ART កាលណាអ្នកជំងឺទទួលបានការផ្តល់ប្រឹក្សាយ៉ាងតិច៣ក្នុងចំណោមចំនុចទាំង៦ខាងលើ ។

- ការបង្ហាញអំពីប្រព័ន្ធគ្រប់គ្រងទិន្នន័យ BCC : បង្ហាញដោយលោកស្រី ឡាញ់ ចរិយា បានលើកឡើងនូវប្រព័ន្ធគំរូរបាយការណ៍ថ្មីដែលមានការកែសំរួលចំនុចមួយចំនួនដែលតំរូវអោយមន្រ្តីគ្រប់គ្រងទិន្នន័យអាចត្រួតពិនិត្យថារបាយការណ៏នេះត្រឹមត្រូវដែររឺទេ នៅពេលបានទទួលពីអ្នកទទួលខុសត្រូវផ្នែក BCC នៅការិយាល័យអេដស៏ខេត្ត មុននិងបញ្ជូនមកកាន់មជ្ឈមណ្ឌលជាតិ

**ថ្ងៃទី ៣ : ថ្ងៃទី ២០ ខែតុលា ឆ្នាំ២០១១**

ពេលព្រឹក

- ការឡើងបង្ហាញជាគំរូក្នុងការបញ្ចូលទិន្នន័យដោយលោក លាង សុផាន់ណា ដោយលើកយកវិធីសាស្រ្តក្នុងការបញ្ចូលពត៌មានរបស់អ្នកជំងឺទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យនិងរបៀបធ្វើការផ្ទៀងផ្ទាត់ឡើងវិញ ដើម្បីអោយទិន្នន័យដែលបានបញ្ចូលមានភាពត្រឹមត្រូវ និងច្បាស់លាស់អាចយកជាការបានព្រមទាំងអាចបោះពុម្ភជារបាយការណ៏ប្រចាំត្រីមាស និងអាចយកទៅធ្វើការសិក្សាស្រាវជ្រាវផ្សេងៗទៀត ។
- ការពិភាក្សា និងផ្លាស់ប្តូរបទពិសោធន៍ អំពីការបញ្ចូលទិន្នន័យរបស់អ្នកជំងឺទៅក្នុង OI-ART Database និង VCCT Database ដោយផ្តល់ឱកាសអោយមន្រ្តីគ្រប់គ្រងទិន្នន័យ និងមន្រ្តីបញ្ចូលទិន្នន័យទាំងអស់ ធ្វើការសាកសួរគ្នាទៅវិញទៅមកអំពីបញ្ហា និងដំណោះស្រាយដែលបានជួបប្រទះ ដើម្បីធ្វើអោយទិន្នន័យដែលពួកគេបានបញ្ចូលមានគុណភាពល្អ ។

ពេលរសៀល

- ការបង្ហាញអំពីការធ្វើរបាយការណ៏គ្រប់ជ្រុងជ្រោយ (Comprehensive Report) ដោយក្រុមការងាររបស់មជ្ឈមណ្ឌលជាតិ, បន្ទាប់មកទៀត បានលើកយករបាយការណ៏របស់មន្រ្តីគ្រប់គ្រងទិន្នន័យខេត្តកណ្តាលមកបង្ហាញ ដើម្បីជួយធ្វើការពិនិត្យ និងកែតំរូវលើចំនុចខ្វះខាតមួយចំនួន សំរាប់អនុវត្តជាបន្តទៀត ។
- ការធ្វើតេស្តក្រោយវគ្គសិក្សា (Post-test) ដែលតំរូវអោយសិក្ខាកាមទាំងអស់បំពេញនូវសំនួរមួយចំនួន ដើម្បីចង់ដឹងថាបន្ទាប់ពីបានទទួលវគ្គបណ្តុះបណ្តាលរយៈពេល៣ថ្ងៃនេះ មកតើកំរិតនៃការយល់ដឹងរបស់ពួកគាត់ស្ថិតនៅកំរិតណា, ណែនាំដោយក្រុមការងាររបស់មជ្ឈមណ្ឌលជាតិ ។

**បញ្ហាដែលជួបប្រទះចំពោះការងារបញ្ចូលទិន្នន័យ**

- ការចុះបញ្ជី OI/ART មិនបានត្រឹមត្រូវ ( លេខកូដជាន់គ្នា)
- ការបំពេញទំរង់ពត៌មានរបស់អ្នកជំងឺមិនទាន់បានគ្រប់គ្រាន់ និងខ្វះខាត ដូចជា កំពស់, ថ្ងៃណាត់ជួប, បរិមាណថ្នាំ, កំរិតថ្នាំ ធ្វើអោយការបញ្ចូលទិន្នន័យមានភាពមិនគ្រប់គ្រាន់តាមនោះដែរ
- ករណីបញ្ជូនចេញ រឺ បញ្ជូនចូល ( ពត៌មានដែលត្រូវបំពេញមិនបានគ្រប់គ្រាន់)
- មានភាពខុសគ្នារវាងការបង្កើតរបាយការណ៏ដោយដៃ និងរបាយការណ៏អេឡិចត្រូនិកដោយប្រព័ន្ធកុំព្យូទ័រ
- ការបញ្ជូនរបាយការណ៍ពីកន្លែងសេវាផ្សេងៗមានការយឺតយ៉ាវ នាំអោយរបាយការណ៍ដែលត្រូវផ្ញើទៅកាន់មជ្ឈមណ្ឌលជាតិមានការយឺតយ៉ាវដែរ
- នៅខេត្តខ្លះមានកុមារដែលទទួល OI/ART មានអាយុលើសពី១៤ ឆ្នាំ ប៉ុន្តែមិនទាន់ញ្ជូនទៅកាន់សេវាមនុស្សពេញវ័យធ្វើអោយការបញ្ចូលពត៌មានរបស់អ្នកជំងឺទៅក្នុង OI/ART Database មិនបានត្រឹមត្រូវ

**សេចក្តីសន្និដ្ឋាន**

បន្ទាប់ពីបានទទួលការសិក្សារយៈពេល ៣ថ្ងៃកន្លងមក ឃើញថាមន្រ្តីគ្រប់គ្រងទិន្នន័យ និងមន្រ្តីបញ្ចូលទិន្នន័យថ្នាក់ខេត្ត-ក្រុងទាំងអស់បានយល់ដឹងបន្ថែមលើការងារថ្មីមួយចំនួនដែលមជ្ឈមណ្ឌលជាតិ បាននិងកំពុងរៀបចំដាក់អោយប្រើប្រាស់មានជាអាទិ៍ : ការងារ Linked Response, Three I's, Positive Prevention, VCCT, Home Base Care, BCC តាមរយៈការបង្ហាញរបស់គ្រូសម្របសម្រួលមកពីមជ្ឈមណ្ឌលជាតិ និងការយកចិត្តទុកដាក់របស់សិក្ខាកាមដែលអាចជួយបង្កើននូវចំណេះដឹងរបស់មន្រ្តីគ្រប់គ្រងទិន្នន័យ មន្រ្តីបញ្ចូលទិន្នន័យ ថ្នាក់ខេត្ត-ក្រុង ក្នុងការប្រមូល, ពិនិត្យ និងធ្វើអោយរបាយការណ៍កាន់តែមានភាពសុក្រិតថែមទៀតមុននិងផ្ញើមកកាន់មជ្ឈមណ្ឌលជាតិ ។

ចំពោះការធ្វើតេស្តមុនវគ្គសិក្សាចំនួនភាគរយដែលសិក្ខាកាមអាចឆ្លើយសំនួរបានត្រឹមត្រូវមាន ៧៥ ភាគរយ ប៉ុន្តែបន្ទាប់ពីបានឆ្លងកាត់វគ្គបណ្តុះបណ្តាលនេះមកឃើញថាសមត្ថភាពរបស់សិក្ខាកាមអាចឆ្លើយសំនួរត្រឹមត្រូវបានច្រើនជាង ៩៥ ភាគរយ នេះអាចបញ្ជាក់អោយកាន់តែច្បាស់ថាវគ្គបណ្តុះបណ្តាលនេះពិតជាមានប្រយោជន៍ដល់សិក្ខាកាមដែលជាមន្រ្តីគ្រប់គ្រងទិន្នន័យ និងមន្រ្តីបញ្ចូលទិន្នន័យខេត្ត-ក្រុងពិតប្រាកដមែន ។

**សំណូមពរ**

- សូមអោយមានវគ្គបណ្តុះបណ្តាលបន្ថែម ដល់អ្នកចុះបញ្ជី និងមន្ត្រីដែលពាក់ព័ន្ធ
- មានការបណ្តុះបណ្តាល រឺ ទស្សនៈកិច្ចសិក្សានៅតាមបណ្តាខេត្តផ្សេងៗ ដើម្បីផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក និងអភិបាលការងារនៅបណ្តាខេត្តដែលខ្លួនធ្វើការ
- សូមមេត្តាជួយរៀបចំការបើកប្រាក់បៀវត្សអោយបានយ៉ាងយូរនៅសប្តាហ៍ទី ១ នៃខែបន្ទាប់
- សូមអោយក្រុមការងារគ្រប់គ្រងទិន្នន័យ បានចូលរួមក្នុងកិច្ចប្រជុំគ្រប់ការងារណាដែលទាក់ទងនិង CoC ដើម្បីស្វែងយល់អំពីការងារ HIV/AIDS នឹងបានផ្តល់យោបល់លើការងារគ្រប់គ្រងទិន្នន័យ

វគ្គបណ្តុះបណ្តាលនេះ បានបញ្ចប់នៅវេលាម៉ោង ១៧:០០ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ដោយមានការចូលរួមក្នុងការប្រកាសបិទវគ្គបណ្តុះបណ្តាលនេះដោយ លោកគ្រូពេទ្យ គុជ វណ្ណា អនុប្រធានមន្ទីរសុខាភិបាលខេត្តមណ្ឌលគីរី ក្រោមបរិយាកាសរីករាយ និងស្និតស្នាលជាទីបំផុត ហើយលោកក៏បានជូនពរអោយសិក្ខាកាមទាំងអស់និងក្រុមការងាររបស់មជ្ឈមណ្ឌលជាតិធ្វើដំណើរទៅកាន់គេហដ្ឋានវិញប្រកបដោយសេចក្តីសុខនិងសុវត្ថិភាព ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០១១

| បានឃើញ និង ឯកភាព | បានពិនិត្យ<br>ប្រធានផ្នែកគ្រប់គ្រងទិន្នន័យ | អ្នកធ្វើរបាយការណ៍ |
|---|---|---|
| វេជ្ជ មាន_ឈីវុន | ម៉ម សុវត្ថា | ប៊ូ វឌ្ឍនះ |